ឆ្នាំ ទី ៧ លេខ ១២ សប្តាហ៍ ទី ២ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៧ រាជកិច្ច ទំព័រ ១៧១០

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១១ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការឈប់ទទួលស្គាល់សាកលវិទ្យាល័យបច្ចេកវិទ្យាភ្នំពេញ

---

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក. ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ. ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យ លេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០២ ស្តីពីការទទួលស្គាល់សាកលវិទ្យាល័យបច្ចេកវិទ្យាភ្នំពេញ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

# ស ម្រេ ច

**មាត្រា ១.-**

បញ្ឈប់ការទទួលស្គាល់គ្រឹះស្ថានឧត្តមសិក្សាឯកជន ដែលមានឈ្មោះថា **សាកលវិទ្យាល័យបច្ចេកវិទ្យាភ្នំពេញ** UNIVERSITY OF TECHNOLOGY PHNOM PENH ហៅកាត់ជាភាសាខ្មែរ "ស.ប.ភ" និងហៅកាត់ជាភាសាអង់គ្លេស "U.T.P.P" ដែលមានទីតាំងស្ថិតនៅអគារលេខ ១៩ ផ្លូវលេខ៣៨០ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**មាត្រា ២.-**

សាកលវិទ្យាល័យបច្ចេកវិទ្យាភ្នំពេញ ត្រូវបញ្ឈប់ការបណ្តុះបណ្តាលគ្រប់កំរិត និងគ្រប់រូបភាព និងត្រូវចេញវិញ្ញាបនបត្រ ដល់និស្សិតទាំងអស់ដែលបានសិក្សានៅសាកលវិទ្យាល័យ តាមកំរិត និងកម្មវិធីសិក្សា ដែលពួកគេបានសិក្សារួចហើយ ។

**មាត្រា ៣.-**

អនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ២០០២ ស្តីពីការទទួលស្គាល់សាកលវិទ្យាល័យបច្ចេកវិទ្យាភ្នំពេញ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ក្រសួង-ស្ថាប័នពាក់ព័ន្ធ និង សាកលវិទ្យាល័យបច្ចេកវិទ្យាភ្នំពេញ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កុម្ភៈ ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- សាលាក្រុងភ្នំពេញ
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ